# ១២- សុភាទន្សាយ

## (ពាក្យរាយតពីពាក្យកាព្យ)

ដំណាលពីរឿងទន្សាយ កាលដែលរត់ពីអណ្តូងទៅនោះ ទៅឈប់នៅជិតភូមិមានយាយចាស់ម្នាក់ទូលចេកទៅលក់ ទន្សាយឃើញគិតថា“ឥឡូវអញអស់កំលាំងម្ល៉េះធ្វើម្តេចនឹងបានចេកនោះស៊ីមានតែធ្វើស្លាប់”គិតហើយក៏លូនទៅដេកនៅផ្លូវ ។ ឯយាយចាស់នោះទូលចេកដើរមកដល់ឃើញទន្សាយគិតស្មានថាជាស្លាប់មែនហើយលាន់មាត់ថា“អុះអញមកលក់ចេកថ្ងៃនេះ ហៅពេញជាមានលាភពន់ពេក អញនឹងយកអាទន្សាយនេះទៅស្លស៊ីបានម្តង”ហើយក៏លើកទន្សាយនោះដាក់ក្នុងល្អីដើរទៅ ។ ទន្សាយនោះកាលបើយាយចាស់ដាក់ទៅលើល្អីចេកហើយ ក៏បកស៊ីៗ ។ លុះយាយចាស់នោះដល់ទៅផ្ទះគេៗហៅទិញចេកគាត់ដាក់កញ្ជើចេកពីលើក្បាលមកទន្សាយវាលោតបោលទៅមើលទៅចេកនៅសល់តែសំបក ។ យាយចាស់នោះថា“ម៉ែ! អាទន្សាយវារស់ទេតើអញស្មានថាវាងាប់” ។ ចេកនោះក៏អស់ខានលក់ទន្សាយនោះក៏វាបោលរួចទៅ ។

ឯទន្សាយកាលបោលពីភូមិនោះឆ្លងចូលទៅក្នុងព្រៃ ចុះទៅក្នុងត្រពាំងមួយប្រុងនឹងផឹកទឹក ។ កាលនោះមានខ្យងក្នុងត្រពាំងនោះវាឃាត់ថា“អាទន្សាយឯងម្តេចក៏មកផឹកទឹកអញ” ។ ទន្សាយឆ្លើថា“ថ្វីបើអញផឹកទឹកផងទឹកម៉ែឪអាណា ?” ។ ខ្យងថា“អើទឹកផងអញ” ។ ទន្សាយឆ្លើយថា“បើដូច្នោះឯងបោលភ្នាល់នឹងអញ អញបោលលើគោកឯងហែលក្នុងទឹកបើឯងហែលលឿនជាងអញៗ ខានផឹកទឹកត្រពាំងនេះ បើអញបោលលឿនជាងឯងអញផឹកទឹកត្រពាំងនេះ” ។

ខ្យងក៏ព្រមភ្នាល់ទើបខ្យងវាគិតគ្នាវាថា“យើងបណ្តាក់គ្នាអោយជុំវិញតែមាត់ត្រពាំងនេះ បើទន្សាយវាស្រែកហៅ កុំអោយអ្នកឯក្រោយឆ្លើយឡើងអោយអ្នកណាដែលនៅឯមុខនោះឆ្លើយឡើង” ។ គិតគ្នារួចស្រេចហើយស្រែកប្រាប់ទៅទន្សាយថា“ទន្សាយនោះវាឆ្លើយថា«កូក»” ។ ទន្សាយថា“ម៉ែ! អានេះហែលលឿនទៅឆ្ងាយណាស់” ។ ទន្សាយបោលទៅទៀតហើយហៅទៀតខ្យងមុខនោះឆ្លើយឡើងទៀតបោលពុំចេះទាន់ឡើយទន្សាយទទួលចាញ់ប្រាជ្ញាខ្យងពុំហ៊ានផឹកទឹកត្រពាំងបឹងបួរឯណាឡើយ ផឹកតែទឹកសន្សើមតាំងពីនោះមក ។

ឯទន្សាយបោលពីនោះទៅទៀត គិតនឹងឆ្លងទៅត្រើយម្ខាង ពុំដឹងគិតធ្វើដូចម្តេចនឹងទៅបាន ។ កាលនោះមានក្រពើមួយហែលចុះឡើង ។ ទន្សាយឃើញហើយគិតថា“អញធ្វើដូចម្តេចនឹងបានអាក្រពើនេះ ចំលងអញទៅដាក់ត្រើយនាយ” គិតហើយធ្វើជាសួរថា“បងក្រពើបងឯងកើតអ្វីបានជាគគ្រាតអស់ទាំងខ្លួន ?” ។ ក្រពើនោះប្រាប់ទៅវិញថា“គេហៅកើតស្រែង” ។ ឯទន្សាយថា“បងចំលងតែអញទៅដល់ត្រើយនាយចុះ អញនឹងមើលស្រែងបងឯងអោយជា” ។ ឯក្រពើឮគេថានឹងមើលអោយជាដូច្នោះក៏អរណាស់ មកឡើងបង្អើលខ្លួនលើគោកហើយថា“អញចំលងអ្នកឯងទៅអ្នកឯងមើលស្រែងខ្ញុំអោយជាចុះ” ។ ទន្សាយថា“អើ! កុំភ័យ” ។ ទន្សាយខ្ញើមក្រពើវាកាច់ស្លឹកឈើទ្រាប់អង្គុយ ។ ក្រពើសួរថា“ចាំទ្រាប់ស្លឹកឈើធ្វើអ្វី ?”ទន្សាយថា“បងឯងមានគុណនឹងខ្ញុំក្រែងវាបាបខ្ញុំ” ។ ហើយទន្សាយឡើងជិះលើក្បាលក្រពើនោះ ។ ឯក្រពើជឿស្មោះចំពោះថាជាត្រង់ពិតមែនខំហែលចំលងបានដល់ទៅត្រើយនាយ ។ ទន្សាយចុះពីលើក្បាលក្រពើបោលឡើងទៅលើគោកហើយស្រែកថា“ស្រែងអាឯងកើតតាំងតែពីជីដូនជីតាអាឯងមកអាណាមើលជា” ។ ក្រពើខឹងណាស់គិតថា“អាទន្សាយនេះវាបញ្ឆោតអញដល់ខ្នាតហើយពុំធ្វើដូច្នេះនឹងខាំវាបាន” គិតហើយធ្វើដូចគល់អណ្តែតទឹករសាត់ចុះឡើង ។ ទន្សាយនោះវាបោលទៅមកឃើញក្របីមួយងាប់នៅមាត់ត្រពាំងធ្មាតរូងពោះក្របីនោះ ក៏ទន្សាយវាចូលលេងដល់ត្រូវថ្ងៃក្តៅ គូថក្របីនោះវាខ្ទិបជិតទន្សាយចេញមកវិញពុំរួចរិលវល់នៅក្នុងពោះក្របីនោះទាល់តែល្ងាច ។ លុះល្ងាចមានមនុស្សមកដងទឹកទន្សាយថា“ ឱអស់លោកអ្នកស្រុក អាណាគិតដងទឹកមក

ស្រោចគូថក្របីនេះអោយទានមេត្តាប្រោសយកតែបុណ្យទៅចុះ លោកបានបុណ្យច្រើនណាស់" ។ អ្នកដងទឹកគេឮច្រើនដង គេក៏ដងទឹកទៅស្រោចគូថក្របីនោះក៏រីកចេញ ។ ទន្សាយវាចេញមកខាងក្រៅរួចហើយវាបោលទៅវាលស្រែថា "គ្មានបានគុណប្រយោជន៍អ្វីទេ អញបញ្ឆោតអោយតែរួចខ្លួនអញទេ" ។ ទន្សាយវាបោលទៅទៀតឃើញក្រពើបណ្ដែតខ្លួនក៏មន្ទិលក្នុងចិត្តថា "នេះជាក្រពើ ឬមួយជាគល់ទេអេះ ?" ។ ទន្សាយគិតដូច្នោះហើយទើបស្រែកថា "បើជាក្រពើទេអោយអណ្ដែតបណ្ដោយទឹក បើជាគល់អណ្ដែតច្រាសទឹកឡើងទៅវិញ" ។ ឯក្រពើឮថាដូច្នោះហើយគិតថា "អញថាធ្វើជាគល់ ឥឡូវគេថាបើគល់អោយអណ្ដែតច្រាសទឹក បើដូច្នោះអញធ្វើជាច្រាសទឹកវិញចុះ" គិតហើយក៏ហែលច្រាសទឹកទៅវិញ ។ ទន្សាយឃើញហើយវាថា "យើ! មើលនែអាក្រពើ អាឯងមកបញ្ឆោតអញ កុំអាបញ្ឆោតមិនបានទេ" ។ ក្រពើឮហើយគិតថា "អញចាញ់ប្រាជ្ញាទន្សាយទៀតហើយ" ទើបគិតទៀតថា "បើដូច្នេះអញឡើងលើគោកធ្វើជាងាប់វិញទើបស្រួល" គិតដូច្នេះហើយក៏ឡើងទៅដេកលើគោកហាមាត់ដូចជាគេងាប់ ។ ឯទន្សាយដើរទៅដើរមកឃើញក្រពើដេកដូច្នោះ គិតថា "អានេះងាប់ហើយតើ" ។ រួចដើរចូលទៅក្នុងមាត់ក្រពើនោះ ហើយអង្អែលចង្កូមលេងថា "អើចង្កូមធំនេះធ្វើដងកាំបិតស្នៀតអញ ចង្កូមតូចនេះធ្វើដងកាំបិតស្លាអោយប្រពន្ធអញកាត់គាត់" ។

កំពុងតែរៀបរាប់ក្រពើត្របាក់ឃុប ។ ទន្សាយបោលប្លូចចូលទៅក្នុងពោះហើយស្រែកថា "ឱ! ជាណាស់ហើយនេះ អញកំពុងតែចង់ស៊ីពោះវៀនបត់ចន្ទាសផង ឥឡូវបានមកដល់ក្នុងពោះហើយ អញស្រាវពោះវៀនបត់ចន្ទាសអាំងស៊ីអោយអស់" ថាហើយក៏ផ្ទាត់ក្រចកឮសូរប្រែះៗ ។ ឯក្រពើឮហើយក៏ភ័យណាស់អង្វរថា "បងទន្សាយអាណិតចេញទៅចុះ ខ្ញុំមិនហ៊ានខាំបងឯងទេ" ។ ទន្សាយថា "អើបើអាឯងអង្វរអញៗអាណិតអញលែងអាឯង" ។ ក្រពើហាមាត់ឡើងហើយទន្សាយនោះបោលចេញទៅ ។

ទន្សាយបោលទៅៗ ឃើញដង្គត់ឈើមួយនៅមាត់ត្រពាំង ឡើងទៅអង្គុយលើដង្គត់ឈើនោះ ។ ដល់ថ្ងៃក្ដៅរលាយជ័រឈើជាប់ឯគូថទន្សាយនៅដង្គត់ឈើទៅ ។

កាលនោះមានកូនដរីមួយមកផឹកទឹកត្រពាំងនោះ ។ ទន្សាយឃើញហើយថា "យើងៗ! ម្ដេចក៏មកផឹកទឹកអញ ? ទេពតាលោកអោយអញចាំនៅទីនេះ" ។ កូនដរីភ័យណាស់ក៏បោលទៅប្រាប់មេ មេឮកូនប្រាប់ដូច្នោះខឹងណាស់ មករកទន្សាយសួរថា "អាទន្សាយឯងម្ដេចក៏មិនអោយកូនអញផឹកទឹក ?" ។ ទន្សាយថា "អើអញមិនអោយផឹកត្បិតទេពតាលោកអោយអញចាំ" ។ មេដរីនោះខឹងណាស់ចាប់ទន្សាយបោះពីនោះទៅចូលក្នុងចំការតាចាស់ម្នាក់ ។ ឯតាចាស់នោះគាត់ដាំត្រសក់ពេញតែចំការ ។ ទន្សាយនោះលួចត្រសក់គាត់ស៊ីតែសព្វថ្ងៃ ។ តាចាស់នោះខឹងណាស់គិតធ្វើអន្ទាក់ដាក់ដល់មួយយប់នោះទន្សាយទៅស៊ីក៏ត្រូវអន្ទាក់តាចាស់នោះ ។ ទន្សាយភ័យណាស់ក្រែងតាចាស់មកទាន់ ។ ពេលនោះមានតីង្គក់មួយលោតចុះលោតឡើង ។ ទន្សាយឃើញហើយក៏អរណាស់ ធ្វើជាសួរថា "អ្នកបងតីង្គក់អ្នកបងកើតអ្វី ?" ។ តីង្គក់នោះប្រាប់ទៅវិញថា "ខ្ញុំកើតស្រែង" ។ ទន្សាយថា ឱអ្នកបង អ្នកបងឯងដោះអន្ទាក់អោយខ្ញុំៗនឹងធានាមើលស្រែងបងឯងអោយជា កុំអោយបងឯងព្រួយចិត្ត ។ តីង្គក់ឮគេថាមើលស្រែងអោយជា ក៏អរណាស់ខំដោះអន្ទាក់អោយទាល់តែរួច ។ ឯទន្សាយបានរួចពីអន្ទាក់ហើយ ក៏និយាយថា "ស្រែងពីដីដូនជីតាអាមកអាណាមើលជា" ។ តីង្គក់ខឹងណាស់ខំលោតដេញតាមគេក៏មិនទាន់ឡើយ ។

និយាយពីតាចាស់គាត់ភ្ញាក់ឡើងពីព្រឹក រៀបវេចស្លាម្លូរួចហើយគាត់ដើរទៅជាប្រញាប់ទៅមើលចំការត្រសក់គាត់ ហើយចូលទៅមើលស្នាមសែដត្រូវទន្សាយរួចទៅនោះ តាចាស់ស្ដាយណាស់គក់ទ្រូងគក់ស្មា "អញខានស្លសាច់ទន្សាយសោះ" ។ គាត់រៀបដាក់ជាថ្មី ដល់យប់ឯក្រោយទៀតទន្សាយនឹកភ្នកចង់ត្រសក់បោលចូលទៅក្នុងចំការភ្លេចនឹកអំពីអន្ទាក់ដោយសារឃ្លានចង់ស៊ីត្រសក់ទៅជាន់លើអន្ទាក់ជាប់ឯជើង ទន្សាយភ័យណាស់មិនដឹងគិតធ្វើដូចម្ដេច នឹងបានរួចពីអន្ទាក់ ។ តីង្គក់មកឃើញទន្សាយជាប់អន្ទាក់ក៏អរណាស់ លោតឡើងទះដៃផ្ដន្ទាថា "ឯងធ្លាប់តែបញ្ឆោតអញ ឥឡូវនេះមកជាប់អន្ទាក់ក្រញោនធ្វើមុខភ្លឺះៗ ដូចជាមុខខ្មោចនរណានឹងជួយឯងទៀត" ។ ឯទន្សាយ

ឮគីង្គក់ផ្ទាន់ផ្ទញ់ផ្ទាល់មកខឹងចិត្តណាស់ ប៉ុន្តែជាសត្វមានប្រាជ្ញា ធ្វើជាមិនខឹងនិយាយលួងលោមគីង្គក់ថា "ពីមុនខ្ញុំបញ្ឆោតបងឯងពីព្រោះខ្ញុំទាល់ចំណេះមិនចេះថ្នាំមើលស្រែងបងឯង ម្តងនេះខ្ញុំនិយាយប្រាកដប្រជាមែនទែន ត្បិតខ្ញុំឃើញកូនក្រមុំគេល្អណាស់មុខកំប្លង់ៗ ថ្ពាល់បំផូរដូចផ្កាកូឡាប ខ្ញុំនឹងទៅដណ្តឹងអោយបងឯងៗកុំព្រួយចិត្ត ត្បិតខ្ញុំបាននិយាយម្តងរួចហើយគេថានឹងអោយជាប្រពន្ធបងឯង បើបងឯងជួយដោះខ្ញុំអោយរួចចេញពីអន្ទាក់ ម្តងនេះខ្ញុំទៅដណ្តឹងអោយកុំព្រួយចិត្ត" ។ គីង្គក់ហេតុតែជាសត្វឆ្កួតនឹងស្រីបានឮទន្សាយនិយាយពីកូនក្រមុំគេដូច្នោះ អរណាស់អត់មិនបានញញឹមញញែមកខ្មេះកខ្មោញចង់បានកូនក្រមុំគេ ហើយនិយាយថា "បងទន្សាយនិយាយអោយមែនទែនកុំបញ្ឆោតខ្ញុំដូចពីមុនទៀត" ។ ទន្សាយឆ្លើយថា "ទេបញ្ឆោតអីច្រើនដងម្ល៉េះពីមុនពីទាល់ចំណេះខ្ញុំបានជាកុហកម្តងនេះវាងាយទេ ត្បិតអ្នកស្រុកអង្គរ មានកូនក្រមុំច្រើនណាស់ ទោះបីខ្ញុំមិនទៅបងឯងទៅដណ្តឹងខ្លួនឯង ក៏គេអោយដែរត្បិតឥឡូវក្រមុំថោកណាស់ ក្រមុំដប់មួយស្លឹក" បានជាពាក្យមនុស្សគេច្រៀងថា "ក្រមុំដប់មួយស្លឹក" ដោយសារឃើញគីង្គក់ហែលទឹកទៅយកប្រពន្ធស្រុកអង្គរ ។ គីង្គក់ក៏ដោះអន្ទាក់អោយទន្សាយទៀត ។ ទន្សាយបានរួចពីអន្ទាក់ហើយ ក៏ស្ទុះផ្លោតលោតបោលទៅហើយថា "គីង្គក់ឯងស្រែងគគ្រាតណាស់ នរណាគេនឹងអោយកូនក្រមុំគេអញបញ្ឆោតឯងទេ" ។ គីង្គក់ឮទន្សាយថាដូច្នោះខឹងណាស់ ចង់តែលោតខ្ទិចក្បាលអោយស្លាប់នឹងភ្លឺស្រែ ប៉ុន្តែមកគិតមានៈក្នុងចិត្ត ចង់បានកូនក្រមុំស្រុកអង្គរហើយក៏ទៅ ។ លុះជួបនឹងសត្វកំពូលអាចម៍ៗ សួរថា " បងគីង្គក់ទៅណា ?" ។ គីង្គក់ប្រាប់ថា "ខ្ញុំទៅយកប្រពន្ធស្រុកអង្គរ" ។

សត្វកំពូលអាចម៍ថា "បងឯងទៅដល់ឬថ្មើរនេះទៅហើយ ?" ។ គីង្គក់នោះពីព្រោះតែចិត្តចង់បានប្រពន្ធណាស់ ក៏ប្រាប់ទៅកំពូលអាចម៍ថា "ខ្ញុំទៅហើយ ខ្ញុំត្រឡប់មកស៊ីបាយព្រឹកវិញ" គីង្គក់ឮកំពូលអាចម៍ធ្វើងួងៗ ក៏សួរថា "បងឯងធ្វើអ្វី ?" ។ កំពូលអាចម៍ប្រាប់ថា "ខ្ញុំក្រឡឹងដុំរទេះ" ។ គីង្គក់សួរថា "ឯងធ្វើដុំរទេះអ្វីខ្លីម្ល៉េះ?" ។ កំពូលអាចម៍ឆ្លើយថា "មិនខ្លីទេ ខ្ញុំគិតនឹងកាត់អោយបានជាពីរកំណាត់អោយគ្រប់មួយសំរាប់តែម្តង" ។ បានជាកំពូលអាចម៍ថាដូច្នោះអោយទាន់ប្រាជ្ញា ដែលគីង្គក់និយាយជំហរថា "ត្រឡប់មកស៊ីបាយព្រឹកវិញ" ។ គីង្គក់ហែលទឹកអំពីស្រុកទន្លេធំគិតទៅយកប្រពន្ធស្រុកអង្គរ បើជួបនឹងសត្វឯណាគេសួរសុទ្ធតែប្រាប់គេថា "ទៅយកប្រពន្ធឯស្រុកអង្គរ" លុះជួបនឹងត្រីទីពោក៏វាត្របាក់លេបស៊ីទៅ ។

និយាយពីទន្សាយការរួចអំពីអន្ទាក់តាចាស់នោះហើយបោលទៅពួននឹងគុម្ពរពាក់មួយ ។ ពេលនោះមានខ្លាវាមួយមកឃើញទន្សាយពួននៅគុម្ពរពាក់នោះ វាលបចង់ខាំទន្សាយស៊ី ។ ឯទន្សាយដឹងថាខ្លាលបចង់ខាំស៊ីខ្លួន ហើយធ្វើជាគ្រហែមថា "អ៊ែម! អញស៊ីដំរីប្រាំមិនស្កាំមាត់ ស៊ីត្រប់ខារតែមួយស្អាបំពង់កដល់ម្ល៉េះ ? ធ្វើម្តេចបានថ្លើមខ្លាមកស៊ីសោះវាស្អាបំពង់ក" ។ ខ្លាឮទន្សាយថាដូច្នោះ ក៏គិតខ្លាចមិនហ៊ានខាំ ហើយទៅបបួលស្វា លុះទៅជួបនឹងស្វាហើយនិយាយប្រាប់ស្វាថា "អាសត្វអីតូចមួយវាថាស៊ីដំរីប្រាំមិនស្កាំមាត់ វាស៊ីត្រប់ខារតែមួយស្អាណាស់ ធ្វើម្តេចនឹងបានថ្លើមខ្លាស៊ីកុំអោយស្អា ខ្ញុំឮដូច្នោះខ្ញុំខ្លាចណាស់" ។ ស្វាឮខ្លានិយាយប្រាប់ក៏សួរទៅវិញថា "សត្វនោះប៉ុណ្ណារូបវាដូចម្តេច ?" ខ្លាប្រាប់ទៅថា "សត្វនោះតូចប៉ុនកដៃហើយមានស្លឹកត្រចៀកវែងកន្ទុយខ្លី" ។ ស្វាឆ្លើយថា "ឱ! នេះគេហៅសត្វទន្សាយអានេះវាជំហរណាស់បងឯងកុំខ្លាចវា" ។ ខ្លាឮស្វាថាដូច្នោះថា "ទេ! បងស្វាខ្ញុំឃើញកំទេចភ្លុកដែលវាស៊ីដំរីសល់នៅនោះមានពាសពេញប្របខ្លួនវា" ។ ឯស្វាថា "ទេមិនមែនទេបងខ្លាឯងទៅនឹងខ្ញុំៗ ជូនបងឯងទៅមើលអោយច្បាស់មែនទែន" ។ ឯខ្លាប្រកែកថា "ទេខ្ញុំខ្លាចវាណាស់ វាថាចង់ស៊ីថ្លើមខ្ញុំបើបងឯងជូនខ្ញុំទៅបើវាដេញមកខាំខ្ញុំហើយបងឯងរត់ឡើងដើមឈើបាត់ទៅ វានឹងខាំខ្ញុំយកទៅស៊ីឥតអំពើ" ។ ស្វាថា "ឱបងឯងឆោតអីម្ល៉េះ បើបងមិនជឿខ្ញុំ បងឯងយកវល្លិ៍មកចងចង្កេះគ្នាអោយជាប់ទាំងពីរនាក់ហើយសឹមទៅ" ។ ខ្លាឮស្វាដូច្នោះក៏បោចវល្លិ៍មកចងចង្កេះទាំងពីរនាក់ជាប់ហើយបបួលគ្នាដើរទៅ ។ ឯទន្សាយកាលដែលឃើញខ្លាទៅវិញក៏ទៅអង្គុយលើដំបូក១ប្របទីនោះ ។ លុះទន្សាយក្រឡេកមើលទៅឃើញខ្លានឹងស្វាចងចង្កេះជាប់គ្នាហើយដើរចូលមកដូច្នោះ ក៏អើតឡើងគ្រហែមថា

“អែមៗ! អាស្វាអញក្រញាំជំពាក់បំណុលអញ ២-៣ឆ្នាំយកអាខ្លាកញ្ចាស់សំគមមួយអោយអញ” ខ្លាឮទន្សាយថាស្វាយកខ្លួនមកជាត់បំណុលអោយវាដូច្នោះ ក៏ភ័យណាស់ស្ទុះបោលទៅដូចគេកន្ត្រាក់ ស្វាដួលផ្កាប់ផ្ងាហាមាត់នឹងស្លឹកក៏មិនរួច ខ្លាប្រឹងតែបោលដូចគេបោកស្វាទៅលើដង្គត់ឈើស្លាប់មាត់ស្ញេញ ហើយខ្លាបោលទៅឆ្ងាយបែរមើលមកក្រោយឃើញមាត់ស្វាស្ញេញដូច្នោះ គិតស្មានថាជាស្វាសើច ក៏ខំប្រឹងកន្ត្រាក់ទាញខ្សែចំណងផ្ដាច់ចេញអំពីចង្កេះ ហើយបោលតែម្នាក់ឯងទៅ ។ ឯទន្សាយលុះដល់ព្រលប់យប់ងងឹត គិតចង់ស៊ីស្រូវសំណាបល្បាស់ខ្ចី ហើយទៅជិតស្រុកគេឃើញសំណាបលាស់ខៀវខ្ចី ស្ទុះលោតចូលទៅស៊ីស្រូវសំណាប ហើយចូលពួនក្នុងព្រៃវិញ ។ ព្រឹកឡើងម្ចាស់សំណាបមកមើលឃើញស្នាមទន្សាយស៊ីសំណាបខូចអស់ម្ចាស់សំណាបខឹងណាស់គិតធ្វើអន្ទាក់ដាក់តាមគន្លងផ្លូវ ដែលទន្សាយចូលទៅស៊ីសំណាបនោះ ។ លុះយប់ទន្សាយចេញមករកសស៊ីសំណាបទៀត ក៏ត្រូវអន្ទាក់ដែលដាក់នោះ ។ ទន្សាយជាប់អន្ទាក់ហើយភ័យណាស់មិនដឹងគិតទៅអង្វរអ្នកឯណាមកជួយដោះ ហើយគិតធ្វើពុតជាងាប់រឹងស្កូក ។ លុះព្រឹកឡើងម្ចាស់អន្ទាក់ភ្ញាក់ពីព្រលឹមក្រោកជាប្រញាប់រៀបខ្លួនប្រាណដើរទៅមើលអន្ទាក់ ឃើញទន្សាយជាប់អន្ទាក់ងាប់រឹងស្កូក ។ ម្ចាស់អន្ទាក់អរណាស់ចូលទៅដោះទន្សាយនោះ ហើយរៀបដាក់អន្ទាក់នោះទៅវិញ ។ ទន្សាយដឹងថាគេដាក់ខ្លួនទៅដីហើយក៏ស្ទុះចូលទៅក្នុងព្រៃបាត់ទៅ ។ ម្ចាស់អន្ទាក់ស្រាប់តែភ្ញាក់ខ្លួនមើលទៅឃើញទន្សាយបោលទៅក្នុងព្រៃហើយក្រោកឡើងគក់ទ្រូងថា “ឱវាចោរទន្សាយពុតខូចណាស់ទេតើអញស្មានថាវាងាប់ ឥឡូវវាបោលទៅព្រៃព្រងើយ អើអត់អោយម្ដង ថ្ងៃក្រោយគង់តែវាភ្លេចត្រចៀកមកត្រូវអន្ទាក់អញទៀតមិនខានទេ” ។លុះដល់ពីរបីថ្ងៃ ទន្សាយនឹកឃ្លានចង់ស៊ីស្រូវសំណាបទៀត ហើយបោលចូលទៅក្នុងស្រែភ្លេចគិតពីអន្ទាក់នោះអាល័យតែនឹកចង់ស៊ីសំណាបក៏ទៅជាប់អន្ទាក់នោះទៀត ។ ទន្សាយលុះជាប់អន្ទាក់ហើយ ភិតភ័យណាស់ មិនដឹងបើនឹងគិតធ្វើដូចម្ដេចអោយរួចទាល់ប្រាជ្ញាធ្វើមុខស្រមេះៗ ។ លុះព្រឹកឡើងម្ចាស់អន្ទាក់មកឃើញទន្សាយជាប់អន្ទាក់អរណាស់ស្ទុះម៉ីម្ហា ចូលទៅដោះទន្សាយចេញពីអន្ទាក់ហើយថា “ឯងធ្លាប់តែមានពុតជាងាប់ម្ដងនេះឯង ធ្វើដូចម្ដេចក៏អញមិនលែងឯងទៀតដែរ អញទុកគ្រាន់តែនឹងមើលមុខឯងត្បិតឯងមានពុតចេះធ្វើជាងាប់” ហើយយកទន្សាយទៅផ្ទះ ។ លុះដល់ផ្ទះហើយក៏យកអង្រុតក្រុងទន្សាយជាប់ ។ ជួនជាព្រឹកនោះ អ្នកនោះបានត្រីរស់មួយយកមកប្រោសទុកក្នុងថ្លាងដាក់ប្របគ្នានឹងទន្សាយ ហើយនឹកភ្ញកឡើងថា “លោកសង្ឃនៅវត្តចេះចាប់យាមពូកែទាយឆុតណាស់ បើដូច្នោះអញនឹងទៅល្បងអោយលោកចាប់យាមមើលជាឆុតមែនឬដូចម្ដេច ?” ហើយអ្នកនោះផ្ដាំប្រពន្ធថា “ឯងមើលទន្សាយនិងត្រីផងក្រែងវារួច” ហើយដើរចូលទៅក្នុងវត្ត ឡើងទៅលើកុដិក្រាបថ្វាយបង្គំលោកពិតពុទ្ធដីកាថា “ខ្ញុំព្រះករុណាឮល្បីថាលោកគ្រូចេះចាប់យាមឆុតណាស់” ។ ឯលោកមានពុទ្ធដីកាថា “ចេះប៉ុន្តែឆុតមិនឆុតមិនហ៊ានអួតទេ” ។ អ្នកនោះឆ្លើយឡើងថា “សូមទានមេត្តាប្រោសទាយឲ្យខ្ញុំករុណាបន្តិច តើក្នុងវេលាព្រឹកនេះឯង និងមានលាភអ្វីទទួលទាន?” លោកនោះឆ្លើយថា “ទេអាចក្ដីមិនហ៊ានទាយទេ” ។ អ្នកនោះថា “សូមទានមេត្តាប្រោសទាយឲ្យទានបន្តិចខ្ញុំករុណាចង់ដឹងនឹងបានអ្វីទទួលទានក្នុងវេលាព្រឹកនេះ” ។ លោកសង្ឃរាជឆ្លើយឡើងថា “ទេក្រែងញោមអន់ចិត្ត” ។ អ្នកនោះគិតក្នុងចិត្តថា “បើលោកនេះទាយត្រូវអញអោយសាច់ទន្សាយ និងត្រីរស់ឆាន់ បើលោកទាយមិនត្រូវអញមិនអោយឆាន់សោះអញស៊ីតែពីរនាក់នឹងប្រពន្ធអញ” នឹកតែក្នុងចិត្តហើយពិតពុទ្ធដីកាលោកថា “ទេខ្ញុំករុណាមិនអន់ចិត្តទេ” ។ លោកយកតម្រាមកមើលហើយទាយថា “ញោមគ្មានលាភអ្វីទេ” ។ អ្នកនោះលាលោកត្រឡប់មកវិញ ហើយនឹកថា “លោកនេះចាប់យាមមិនឆុតទេអញគិតស្មានក្រែងលោកទាយត្រូវនឹងប្រគេនសម្លលោកឆាន់ ឥឡូវនេះលោកទាយមិនត្រូវដូច្នេះអញស៊ីតែពីរនាក់ប្រពន្ធអញ” គិតដូច្នោះហើយដើរមកដល់ផ្ទះបង្គាប់ប្រពន្ធអោយដណ្ដាំបាយ ។

ឯទន្សាយ និង ត្រីរស់គិតគ្នាថា “បងត្រីឯងធ្វើជាងាប់ផ្ងារពោះបើគេមកចាប់បងឯងទៅកាប់ស្លស៊ី ហើយគេដាក់បងឯងនៅប្របទឹក បងឯងលោតចុះទៅក្នុងទឹកបងឯង

ធ្វើជាហែលផែលៗ បន្តិចៗ បើគេលោតទៅចាប់បងឯងៗ ស្ទុះហែលទៅបន្តិចធ្វើជាផ្ងារពោះទៀត អោយគេមកយកអង្រុតដែលគេគ្របខ្ញុំទៅរុតចាប់បងឯង ឃើញគេយកអង្រុតទៅបងឯងស្ទុះហែលអោយបាត់ទៅ" ។ ឯជនទាំងពីរនាក់ប្តីប្រពន្ធលុះប្រពន្ធដណ្តាំបាយឆ្អិនហើយ ប្តីយកត្រីទៅស្រការនៅមាត់ត្រពាំងនៅមុខផ្ទះ ។ ត្រីធ្វើជាងាប់ផ្ងារពោះរឹងស្តូកមិនកំរើកខ្លួនសោះ បុរសនោះគិតស្មានថា ងាប់ ចាប់យកត្រីទៅប្របមាត់ត្រពាំងជិតមាត់ទឹក ត្រីក៏ស្ទុះផ្លោតលោតចុះទៅក្នុងទឹកធ្វើតាមពាក្យទន្សាយផ្តាំសព្វគ្រប់ ។ ឯបុរសនោះឃើញត្រីលោតចូលទៅក្នុងទឹកហែលផែលៗ ដូច្នោះក៏លោតទៅចាប់ ។ ត្រីស្ទុះទៅទៀតហើយធ្វើជាផ្ងារពោះផែលៗ ដូច្នេះពីរបីដងអ្នកនោះចាប់មិនបាន ស្រែកហៅទៅប្រពន្ធអោយយកអង្រុតទៅជាប្រញាប់ ។ ប្រពន្ធមិនបានជាគិតដល់ទន្សាយ ក៏លោតកញ្ឆក់យកអង្រុតទៅអោយប្តីរុតត្រីត្រពាំងទាំងពីរនាក់ប្តីប្រពន្ធទទឹកសំពត់អាវអស់ ។ ត្រីឃើញអង្រុតក៏ស្ទុះហែលទៅក្នុងទឹកជ្រៅបាត់ទៅ ។ បុរសប្តីប្រពន្ធខឹងណាស់ខំរុតរកត្រី ពុំឃើញសោះរងាណាស់ទ្រាំមិនបាន ពីព្រោះរដូវខែខ្យល់ពីជើងហើយពីព្រឹកព្រហាមផងញ័រទាំងដៃជើងរណ្តំទាំងធ្មេញ ។ ទាំងពីរនាក់ប្តីប្រពន្ធរត់ឡើងមកអាំងភ្លើងជើងក្រានដែលដណ្តាំបាយនោះ អង្គុយច្រហោងទាំងពីរនាក់ទល់មុខគ្នា ក៏នឹកឃើញទំនាយដែលលោកសង្ឃរាជចាប់យាមថា គ្មានលាភអ្វីទេ ... ត្រូវតាមលោកចាប់យាមអោយនោះឯង ។ អ្នកនោះក៏ជឿលោកគ្រូនោះថា ចាប់យាមឆុតពូកែមែន ។

## ត្រីរស់ក៏រួច ទន្សាយក៏រួច